**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

*ក្រសួងមហាផ្ទៃ*

**អគ្គលេខាធិការដ្ឋាន**

**ការប្រញាប់**

# កំណត់បង្ហាញលិខិតចូល

**ក្រសួង ខេត្ត ក្រុង ផ្ញើ** អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា **លេខ** ១៩/២៣ **ចុះថ្ងៃទី** ១៨.ឧសភា.២០២៣

**កម្មវត្ថុ:** សូមគោរពអញ្ជើញ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឬតំណាងមួយរូប ចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាកម្មករក្រោមប្រធានបទ "សរសៃឈាមស្ត្រីក្នុងវិស័យការងារ" នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ០៨:០០នាទីព្រឹក ដល់ម៉ោង១២:៣០នាទីថ្ងៃត្រង់ នៅសណ្ឋាគារតារាអ៊ែផត។

**ខ្លឹមសារសង្ខេប**:

**សូមគោរពជូន** លោកប្រធាននាយកដ្ឋានមេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

-គួរគោរពជូន **ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ និងស្នើជូន **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២៣

**ប្រធានការិយាល័យរបៀប**

ឈើង_វ៉ន

## យោបល់អនុរដ្ឋលេខាធិការទទួលបន្ទុក

## យោបល់រដ្ឋលេខាធិការទទួលបន្ទុក

24.05.23

សក់_សេដ្ឋា

## យោបល់នាយកដ្ឋាន

**សូមគោរពជូន:ឯកឧត្តម អគ្គលេខាធិការ**

-គួរគោរពជូន **ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ និងស្នើជូន **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

23/05/23

ឧត្តមសេនីយ៍ត្រី ផាត់_ផល

## យោបល់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## យោបល់អគ្គលេខាធិការ

**សូមគោរពជូន: ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

-គួរជូន **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

23-05-23

ម៉ែន ប៊ុនរិទ្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ចូល លេខ: ១៧៤/២៣ ថ្ងៃទី២៥ ខែ៥ ឆ្នាំ២០២៣

**គោរពជូន**
**សម្តេចក្រឡាហោម ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

លេខ: ១៩/២៣

ក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាន
ចូល លេខ 435 ថ្ងៃ 18.05.23

**កម្មវត្ថុ** ៖ សូមគោរពអញ្ជើញ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឬតំណាងមួយរូប ចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាកម្មករ ក្រោមប្រធានបទ *"សរសៃឈាមស្ត្រីក្នុងវិស័យការងារ"*។

**យោង** ៖ លិខិតក្រសួងមហាផ្ទៃលេខ ៧២៦ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨
លិខិតក្រសួងមហាផ្ទៃលេខ ៣៣៥២ ស.ជ.ណ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា យើងខ្ញុំជាកម្មការិនីកម្មករ អ្នកប្រកបរបរផ្លូវភេទ និងគាំទ្របច្ចេកទេសពីអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា រួមសហការជាមួយសមាគមមណ្ឌលព័ត៌មានកម្មករ រៀបចំវេទិកាកម្មករ ដែលនឹងប្រព្រឹត្តិទៅនៅ ***ថ្ងៃអាទិត្យ ទី២៨ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង០៨:០០នាទីព្រឹក ដល់ម៉ោង១២:៣០នាទីថ្ងៃត្រង់ នៅសណ្ឋាគារតារា-អ៊ែផត មានអាសយដ្ឋាននៅជាន់ទី៨ ស្ថិតនៅក្នុងផ្សារទំនើបរតនាផ្លាហ្សា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ***។ វេទិកានេះរៀបចំឡើងក្នុងគោលបំណងចំនួនបីគឺ *១) អបអរសាទរទិវាពលកម្មអន្តរជាតិលើកទី១៣៧ និងរំលឹកដល់វីរភាព ការតស៊ូរបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ ២) បង្កើនលំហរទំនាក់ទំនង និងសាមគ្គីភាពរបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ និង៣) បង្ហាញស្ថានភាពរស់នៅ និង ការងាររបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ និងជំរុញឲ្យមានតម្លាភាព ក៏ដូចជាការទទួលខុសត្រូវពីអ្នកពាក់ព័ន្ធ*។

អាស្រ័យដូចបានគោរព និងជម្រាបជូនខាងលើ យើងខ្ញុំសង្ឃឹមថា **សម្តេចក្រឡាហោម** ឬតំណាងមួយរូប នឹងផ្តល់កិត្តិយសអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស នៅក្នុងវេទិកាកម្មករនេះដោយក្តីអនុគ្រោះ។

សូម **សម្តេចក្រឡាហោម**មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

សូម **សម្តេចក្រឡាហោម**មេត្តាផ្តល់ការឆ្លើយតបមកយើងខ្ញុំវិញត្រឹម**ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣** តាមរយៈលេខទំនាក់ទំនងខាងក្រោម។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣

*ភ្ជាប់ជូនជាមួយនូវ៖*
*- របៀបវារៈកម្មវិធី ចំនួន ១ច្បាប់*
*- ពង្រាងសំណួរសម្រាប់វាគ្មិនកិត្តិយសចំនួន ១ច្បាប់*
*- លិខិតចុះបញ្ជីនៅក្រសួងមហាផ្ទៃ ចំនួន ២ច្បាប់*
*ព័ត៌មានបន្ថែមសូមទំនាក់ទំនងលេខ៖*
*០៩៣ ៨១៦ ៧៣៧/០១២ ៥៧៦ ៣៤៦*

| **មន្ត្រីគាំទ្រផ្នែកច្បាប់** | **ប្រធានអង្គការ** |
|---|---|
| **កញ្ញា ចាន់ ស្មើ** | **លោកស្រី ប៉ិច ប៉ូឡែត** |
| សមាគមមណ្ឌលព័ត៌មានកម្មករ | អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា |

## ពង្រាងសំណួរសម្រាប់វាគ្មិនកិត្តិយសក្នុងកម្មវិធី វេទិកាការងារ
## ប្រធានបទ «*សុវត្ថិភាពស្ត្រីក្នុងវិស័យការងារ*»
## កាលបរិច្ឆេទ ៖ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០២៣
## ទីកន្លែង ៖ សណ្ឋាគារ តារាអ៊ែរផត រាជធានីភ្នំពេញ

នៅក្នុងកិច្ចពិភាក្សាស្ដីពីស្ថានភាពការងាររបស់កម្មករក្នុង និងក្រៅប្រព័ន្ធ យើងខ្ញុំមានសំណើរ និងសំណួរជូនវាគ្មិនដូចខាងក្រោម៖

១. ការចែករំលែកទាក់ទងនឹងការតាមដាន ការអនុវត្តច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ កន្លងមក។
២. ក្រោមការអនុវត្តច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបាន ធ្វើឲ្យអ្នកប្រកបរបរផ្លូវស្ម័គ្រចិត្ត និងជានីតិជនជាច្រើននាក់ ត្រូវបានចាប់ខ្លួន និងទទួលរងអំពើហិង្សា តើក្រសួងមហាផ្ទៃ យល់យ៉ាងណាដែរទៅលើបញ្ហាទាំងនេះ?
៣. តើក្រសួងមហាផ្ទៃមានយន្តការអ្វីខ្លះ ដើម្បីធានាថាមន្ត្រីនៅតាម មូលដ្ឋានបានអនុវត្ត តួនាទី និងភារៈកិច្ចរបស់ខ្លួន និងបានបម្រើប្រជាពលរដ្ឋបានល្អ ជាពិសេសកម្មការិនីក្នុង និងក្រៅប្រព័ន្ធ?
៤. តើក្រសួងមហាផ្ទៃមានផែនការបន្តអ្វីខ្លះ ដើម្បីធានាសន្តិសុខ សុវត្ថិភាព ក៏ដូចជាចូលរួមចំណែកក្នុងការលុបបំបាត់ ការរើសអើង និងអំពើហិង្សាលើស្ត្រី ជាពិសេសអ្នកប្រកបរបរផ្លូវភេទ?

# វេទិកាកម្មករ

## ប្រធានបទ «*សរសៃឈាមស្ត្រីក្នុងវិស័យការងារ*»

## កាលបរិច្ឆេទ ៖ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០២៣

## ទីកន្លែង ៖ សណ្ឋាគារ តារាអ៊ែផត រាជធានីភ្នំពេញ

**គោលបំណង៖**

*១) អបអរសាទរទិវាពលកម្មអន្តរជាតិ លើកទី១៣៧ និងរំលឹកដល់ វីរភាព និងការតស៊ូរបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ*

*២) បង្កើនលំហរទំនាក់ទំនង និង សាមគ្គីភាពរបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ*

*៣) បង្ហាញស្ថានភាពរស់នៅ និង ការងាររបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ និងជំរុញឲ្យមានតម្លាភាព និងការទទួលខុស ត្រូវពីអ្នកពាក់ព័ន្ធ។*

**របៀបវារៈ៖**

| ពេលវេលា | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ០៧:៣០ - ០៨:០០ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ |
| ០៨:០០ - ០៨:១៥ | កិច្ចស្វាគមន៍បើកកម្មវិធី គោរពភ្លេងជាតិ និងដួងវិញ្ញាណកន្ធកម្មការិនីកម្មករដែលបានពលីជីវិត | ពិធីការិនី |
| ០៨:១៥ - ០៨:២០ | ចំរៀង «ជីវិត និងការងារ» | ក្រុមតន្ត្រីយុវវ័យនាំសារ |
| ០៨:២០ - ០៨:៣៥ | បង្ហាញវីដេអូ«នរណាជាអ្នកទទួលខុសត្រូវ?» | អ្នកបច្ចេកទេស |
| ០៨:៣៥ - ០៨:៥០ | សម្តែងរឿងខ្លី | កម្មការិនីកម្មករ |
| ០៨:៥០ - ០៩:៤០ | **កិច្ចពិភាក្សាអំពី «ស្ថានភាពការងាររបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ»**<br>១) តំណាងមកពីក្រសួងមហាផ្ទៃ<br>២) តំណាងមកពីក្រសួងទេសចរណ៍<br>៣) តំណាងមកពីក្រសួងពាណិជ្ជកម្ម<br>៤) កម្មការិនីរោងចក្រកាត់ដេរ<br>៥) អ្នកប្រកបរបរផ្លូវភេទ | អ្នកសម្របសម្រួល |
| ០៩:៤០ - ១០:១០ | សំណួរ និងចម្លើយ | អ្នកចូលរួម |
| ១០:១០ - ១០:២៥ | សម្រាកអាហារសម្រន់ | ក្រុមការងារ |
| ១០:២៥ - ១០:៣០ | ចំរៀង «តតាំង» | ក្រុមតន្ត្រីយុវវ័យនាំសារ |
| ១០:៣០ - ១០:៤៥ | បង្ហាញវីដេអូ «ស្ថានភាពអ្នកប្រកបរបរផ្លូវភេទ» | អ្នកបច្ចេកទេស |

| | | |
|---|---|---|
| ១០:៤៥ - ១១:៤៥ | **កិច្ចពិភាក្សា «ស្ថានភាពរស់នៅរបស់កម្មការិនីកម្មករក្នុង និងក្រៅប្រព័ន្ធ»**<br>១) តំណាងមកពីក្រសួងសុខាភិបាល<br>២) តំណាងមកពីរដ្ឋករទឹកស្វយ័តកម្ពុជា<br>៣) តំណាងអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ<br>៤) អ្នកប្រកបរបរផ្លូវភេទ<br>៥) កម្មការិនីរោងចក្រកាត់ដេរ | អ្នកសម្របសម្រួល |
| ១១:៤៥ - ១២:១០ | សំណួរ និងចម្លើយ | អ្នកចូលរួម |
| ១២:១០ - ១២:១៥ | ចំរៀង «ធាតុពិតនៃសំលៀកបំពាក់ស្អាត» | ក្រុមតន្ត្រីយុវវ័យនាំសារ |
| ១២:១៥ - ១២:២៥ | អានសេចក្តីថ្លែការណ៍រួម | កម្មការិនី |
| ១២:២៥ - ១២:៣០ | សង្ខេប និងប្រកាសបិទកម្មវិធី | ប៊ិច ប៉ូឡែត |
| ១២:៣០ - ០១:៣០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | ក្រុមការងារ |

*យើងខ្ញុំសូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់!*

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ១៧២៦ សជណ

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨

**ជម្រាបមក**
**លោកស្រី សាន វណ្ណារី**
**ប្រធានអង្គសន្និបាត នៃអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា**

**កម្មវត្ថុ** : អំពីសំណើសុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ព្រមទាំងប្តូរលក្ខន្តិកៈអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា។

**យោង** :- ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ ៤៣៣ សជណ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ០០៦/១៨ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ របស់អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកស្រីប្រធានថា ក្រសួងមហាផ្ទៃ បានយល់ព្រមតាមសំណើសុំរបស់អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាល តាំងនៅផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក្នុងការប្តូរលក្ខន្តិកៈ និងការផ្លាស់ប្តូរប្រធាន ព្រមទាំងសមាសភាពថ្មី នៃរចនាសម្ព័ន្ធរបស់អង្គការ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម៖

| ល | គោត្តនាម និងនាម | ភេទ | តួនាទី | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១.សមាសភាពក្រុមប្រឹក្សាភិបាល | | | | |
| ១ | **សាន វណ្ណារី** | ស្រី | ប្រធាន | |
| ២ | **សួន សុខសោភា** | ស្រី | សមាជិកា | |
| ៣ | **ម៉ិច ម៉ូឡែត** | ស្រី | សមាជិកា | |
| ២.សមាសភាពគណៈកម្មការប្រតិបត្តិ | | | | |
| ១ | **ម៉ិច ម៉ូឡែត** | ស្រី | ប្រធាន | |
| ២ | **លឹម សុខផារី** | ស្រី | រដ្ឋបាល/ហេរញ្ញិក | |

ទន្ទឹមនេះ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ សូមលោកស្រីប្រធានជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តតាមការគួរ។

**ជ.រដ្ឋមន្ត្រី**
**អនុរដ្ឋលេខាធិការ**

**ប៊ុន-ហុន**

**ចម្លងជូន ៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចក្រឡាហោម
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
"ដើម្បីជូនជ្រាប"
-ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ៣៣៤២ សជណ

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៩

**ជម្រាបមក**
**លោកស្រី ម៉ាក ច័ន្ទស៊ីថា**
**ប្រធានសមាគមមណ្ឌលព័ត៌មានកម្មករ**

**កម្មវត្ថុ** ៖ ស្តីពីការជូនដំណឹងផ្លាស់ប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលរបស់សមាគមមណ្ឌលព័ត៌មានកម្មករ។

**យោង** ៖ - ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- លិខិតលេខ២៨២៧ សជណ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ៧៥៨ សជណ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ០៤២/២០១៩ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់សមាគមមណ្ឌលព័ត៌មានកម្មករ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកស្រីប្រធានថា ក្រសួងមហាផ្ទៃ យល់ព្រមស្តីពីការផ្លាស់ប្តូរអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលរបស់សមាគមមណ្ឌលព័ត៌មានកម្មករពីផ្ទះលេខ៣-៤ ផ្លូវលេខ៣៣៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ មកតាំងនៅផ្ទះលេខ១៦៨អាហ្វ្រិក ផ្លូវលេខ២៧បេតេ សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នោះហើយ។

ចំពោះការផ្លាស់ប្តូរទីស្នាក់ការរបស់សមាគមមណ្ឌលព័ត៌មានកម្មករនេះ សាមីសមាគមត្រូវជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ព្រមទាំងផ្តល់កិច្ចសហការឲ្យបានល្អក្នុងការអនុវត្តសកម្មភាពការងាររបស់ខ្លួន។

អាស្រ័យហេតុនេះ សូមលោកស្រីប្រធាន ជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តតាមការគួរ។

**ជ - រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ប៊ុន-ហុន**

**<u>ចម្លងជូន</u> ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  "<u>ដើម្បីជូនជ្រាប</u>"
- សាលារាជធានីភ្នំពេញ
  "<u>ដើម្បីមុខការ</u>"
- ឯកសារ - កាលប្បវត្តិ